# គុណមាតាបិតា

អរហំនាមោសិរិសារាប ឱនកាយបន្ទាបសូមក្រាបវន្ទា
សូមពោលសំដែងថ្លែងពណ៌នា វន្ទាគោរពព្រះគុណថ្លាថ្លៃ ។
មាតាបិតាបានបង្កើតកាយ មានគុណជ្រៅឆ្ងាយនិងហួសវិស័យ
ធ្ងន់លើសប្រថពីឥតឧបមេយ្យ ធ្ងន់ហួសវិស័យភ្នំសុមេរា ។
កាលកូនបដិសន្ធិក្នុងឧទរ មាតាថ្នមទ្រគ្រប់ឥរិយា
លុះដល់ប្រសូត្ររួចហើយកាលណា មាតាប្រទាននូវទឹកដោះថ្លៃ ។
បីបមថ្នមទ្រព្រមទាំងពរលាង បញ្ចេញសូរសៀងម៉ែច្រៀងបំពេរ
បបោសអង្អែលថើបសព្វកាយេ ព្រះមេមានគុណឥតគណនា ។
សូមលើកហត្ថាបង្គំក្រាបថ្វាយ ឱពុកអ្នកម្ដាយជាទីជ្រះថ្លា
ធ្លាប់បីថ្នាក់ថ្នមថែទាំរក្សា ដោយចិត្តមេត្តាមិនដែលសៅហ្មង ។
កាលនៅពីតូចពុំទាន់ដឹងក្ដី បញ្ចុកចំណីបំបៅដោះផង
ផ្ចូតទឹកដុសលាងសំអាតច្រើនដង លើកឡើងត្រកងដាក់លើកម្រាល ។
ពេលគេងអ្នកម្ដាយនៅជិតអាត្មា មិនហ៊ានទៅណាឃ្លាតឆ្ងាយខុសកាល
សម្ងំស្ងៀមស្ងាត់មើលអភិបាល ធ្វើការស្រាលៗខ្លាចភ្ញាក់ពិសី ។
ពេលគេងអង្រឹងទាញយោលជានិច្ច មិនឱ្យទង្គិចប៉ះលើអ្វីៗ
ក្រែងលោកូនភ័យបាត់បង់ស្មារតី តែងតែប្រណីដល់កូនសម្លាញ់ ។
អ្នកម្ដាយត្រេកអររីករាយក្រៃពេក ឃើញកូនបានដេកលក់ស្រួលយ៉ាងឆ្ងាញ់
លោករំងាប់ចិត្តពុំមានគ្នាន់ក្នាញ់ ពេញចិត្តស្រឡាញ់ចំពោះកូនម្ដាយ ។
លុះកូនធំឡើងចូលរៀនសាលា នៅតែករុណាផ្គត់ផ្គង់ចំណាយ
លុយកាក់ប្រាក់កាសមិនដែលនឹកស្ដាយ ទុកឱ្យកូនចាយស៊ូអត់ខ្លួនឯង ។
កំពុងរៀនសូត្រវិជ្ជាមួយណា មិនមានរអាប្រាជ្ញាចាត់ចែង
រៀនចាំឆាប់ចេះតាមព្រះសម្ដែង មិនព្រួយចំបែងស្រួលត្រជាក់ចិត្ត ។
ផ្លូវលោកផ្លូវធម៌កូនចេះបានល្អ ប្រសើរបវរលំអរគំនិត

យកធម៌ទីពឹងដើម្បីប្រព្រឹត្ត
ធម៌អាថ៌មែនពិតពីព្រះសម្ពុទ្ធ ។
អ្វីៗទាំងអស់ក្នុងនាលោកិយ
ពុំមានសិរីជាភ្លើងឆេះដុត
បំផ្លាញសត្វលោកពុំអាចតយុទ្ធ
គ្មានទីបំផុតវិលកើតវិលស្លាប់ ។
ផ្លូវធម៌នាំសត្វចេញពីវដ្តៈ
មិននៅប្រឡាក់ឱ្យគេចាក់កាប់
មានច្រកដើរចេញរួសរាន់ប្រញាប់
ព្រោះធ្លាប់បានស្ដាប់ធម៌ព្រះទ្រង់ត្រាស់។
គុណម្ដាយឪពុកគ្មានអ្វីប្រៀបស្មើ
ជួយជូនដំណើរដល់កូនឥតខ្វះ
តាំងពីកើតមករហូតដល់ចាស់
ផ្ដល់សុខច្រើនណាស់ពុំអាចគណនា ។
អាសូរម្ដាយណាស់ពពោះគ្រប់ខែ
លំបាកឥតល្ហែច្រើនពុំសូវជា
ជួនឈឺជួនឃ្លានជួនរងា
ទំរាំស្ងួនភ្ងាប្រសូតចាកផ្ទៃ ។
កូននឹកសែននឹកឪពុកអ្នកម្ដាយ
ទូន្មានក្បោះក្បាយពីរោះមានន័យ
មិនឱ្យប្រព្រឹត្តខុសប្រពៃណី
តាមធម៌ប្រពៃទើបជាមង្គល ។
កូនអង្គុយស្ដាប់ចាប់យកសំដី
មួយម៉ាត់ណាក្ដីចាំស្ទាត់ហើយយល់
គោរពប្រតិបត្តិមិនឱ្យអំពល់
ខំប្រឹងរវល់ធ្វើត្រាប់ព្រះមេ ។
ពេលណាកូនឈឺអ្នកម្ដាយស្វះស្វែង
ឪពុករវែងព្រួយមិននៅទំនេរ
រកថ្នាំព្យាបាលរិះគិតគ្មានគ្នេរ
សួរឯងសួរគេរត់រកពេទ្យហ្ម ។
ពេលកូនបានជាសះស្បើយធូរចិត្ត
អង្គុយបក់ផ្លិតសាទរអបអរ
ទោះបានអ្វីៗមិនស្មើអំណរ
គឺជាផលល្អកម្រកើតមាន ។
ឪពុកអ្នកម្ដាយកូនសប្បាយណាស់
ដោយបានដឹងច្បាស់អ្នកម្ដាយធ្វើទាន
ដល់សត្វទូទៅកំពុងស្រេកឃ្លាន
មានដល់ពួកព្រាហ្មណ៍សមណៈផងដែរ ។
ទាននេះជាស្បៀងសម្រាប់ធ្វើផ្លូវ
គំនិតយល់ត្រូវត្រង់ដូចជាខ្សែ
ជាអរិយទ្រព្យកប់ទុកហូរហែរ
ដូចដួងព្រះខែរះពេញបូណ៌មី ។
ការសន្សំបុណ្យនាំមកនូវសុខ
បានស្រួលស្រណុកមានទាំងរស្មី
បន្តិចម្ដងៗទោះច្រើនតិចក្ដី
គួរតែមេត្រីធ្វើបុណ្យគ្រប់គ្នា ។
យើងខ្ញុំទាំងអស់បុត្រាបុត្រី
លើកហត្ថទាំងទ្វីគោរពវន្ទា
មាតាបិតាចាស់ព្រឹទ្ធាចារ្យ
ករុណាមានគុណអនេកអនគ្ឃ ។
ឥឡូវកូនចៅសូមខមាទោស
ដែលមានកំហុសឆ្គាំឆ្គងទាំងអស់

ទាំងផ្លូវកាយចិត្តសប្បាយឡេះឡោះ វាចាមិនស្មោះតពោលមុសា ។
ពេលខ្លះក្រោធខឹងកូនពោលអាក្រក់ សំឡឹងសំឡក់គ្មានពិចារណា
ពោលស្តីតមាត់មាតាបិតា មានចិត្តទោសាដល់លោកទាំងពីរ ។
កំហុសទាំងអស់កូនធ្វើហើយ ខុសឆ្គងឥតស្បើយមានក្នុងជីវី
កាលនៅជាមួយពុកម្តាយទាំងពីរ ជនកជននីប្រសើរថ្លៃថ្លា ។
សូមលោកខន្តីអភ័យនូវទោស ដែលកូនធ្វើខុសទាំងអម្បាលណា
ចំពោះបុព្វការីមាតាបិតា សូមលោកករុណាមេត្តាប្រណី ។
កូននឹងប្រព្រឹត្តសុចរិតធម៌ សាងកុសលល្អចិន្តាប្រពៃ
សន្សំផលបុណ្យសាងបារមី និងធ្វើព្រះទ័យឱ្យលោកជ្រះថ្លា ។
អំណាចគុណបុណ្យព្រះពុទ្ធព្រះធម៌ ព្រះសង្ឃបវរជាត្រៃសរណា
វត្ថុស័ក្តិសិទ្ធិឥន្ទ្រព្រហ្មទេព្តា មានលើលោកាសព្វស្ថានទី ។
បុណ្យខួបនៃវត្តមុនីសុតា បុណ្យមហាកតញ្ញូកតវេទី
ធ្វើជូនមាតា បិតាថ្លាថ្លៃ លោកត្រេកអរក្រៃវិសេសកន្លង ។
ដោយតេជៈបុណ្យផលានិសង្ស កូនលើកកំបង់អញ្ជលីផ្សង
សូមអ្នកមានគុណបានរួចចំណង ឆ្លងផុតពីទុក្ខទាំង១២កង ។
សូមបានពុទ្ធពរទាំងបួនប្រការ អាយុជន្មារាប់រយឆ្នាំផង
វណ្ណៈសម្បុរល្អម៉ត់ផូរផង់ សុខៈកន្លងទុក្ខកម្មវេរា ។
សូមបានសម្បត្តិទាំងបីប្រការ សម្បត្តិមនុស្សាទាន់ព្រះសិរអារ្យ
សម្បត្តិទេព្តាទាន់ព្រះសមោធាន សម្បត្តិនិព្វានសមដូចប្រាថ្នា ។

# ដឹកចិត្តមាតាបិតា

អហំនាមោសិរោរាប ឱនកាយបន្ទាបក្រាបវន្ទា
សូមពោលសំដែងថ្លែងពណ៌នា វន្ទាគោរពព្រះគុណថ្លៃ ។
មាតាបិតាបង្កើតកាយ មានគុណជ្រៅឆ្ងាយហួសវិស័យ
ធ្ងន់លើសប្រថពីឥតឧបមេយ្យ ធ្ងន់ហួសវិស័យភ្នំសុមេរា ។
កាលកូននៅក្នុងព្រះឧទរ មាតាថ្នមទ្រគ្រប់ឥរិយា

លុះដល់ប្រសូត្ររួចកាលណា
មាតាប្រទានទឹកដោះថ្លៃ ។
បីបមថ្នមទ្រនិងពរលាង
បញ្ចេញសូរសៀងច្រៀងបំពេរ
បបោសអង្អែលសព្វកាយេ
ព្រះមេមានគុណដ៏ជ្រៅឆ្ងាយ ។
បពិត្រមាតានិងបិតា
កូននឹកខ្លោចផ្សារដល់គុណម្ដាយ
តាំងពីកូនកើតមានរូបកាយ
លោកតែងខ្វល់ខ្វាយថែរក្សា ។
ឱៈឱ! ម្ចាស់ថ្លៃវិសេសលន់
លោករងទុក្ខធ្ងន់ពេកណាស់ណា
ព្រោះលោកខំផ្ដេកផ្ដិតចិត្តមេត្តា
ពុំអាចពណ៌នាឱ្យអស់បាន ។
ហេតុនេះកូនសូមផ្គងអញ្ជលី
លើកហត្ថទាំងទ្វីបន្ទន់ប្រាណ
បង្គំបាទាព្រះក្សេមក្សាន្ត
ទោសខុសប៉ុន្មានសូមប្រណី ។
ម្ចាស់អើយកាលកូនទ្រហោរយំ
លោកស្ទុះមកថ្នមត្រកងបី
ច្រៀងបំពេរកូនដោយប្រិមប្រិយ
ដោយពាក្យមេត្រីផ្ដេកបុត្រភ្ងា ។
ទឹកមាត់ទឹកមូត្រលាមកផង
នឹងគ្រឿងសៅហ្មងផងនានា
លោកកាន់លោកចាប់លោកប្រវា
លាងដោយហត្ថាឥតជិនឆ្អន់ ។
បពិត្រលោកម្ដាយមានករុណា
បិតាមានគុណវិសេសលន់
កូនសូមគោរពព្រះគុណធ្ងន់
សូមព្រះសោភ័ណបានក្សេមក្សាន្ត ។
ហេតុនេះកូនសូមឧទ្ទិសផល
ដំកល់ចេតនាដ៏ក្លាហាន
ទានសីលភាវនាដែលកូនបាន
កសាងទាំងប៉ុន្មានសូមជូនទៅអ្នក ។
សូមលោកទទួលដោយសោមនស្ស
ចិត្តខ្ញុំត្រង់ស្មោះចំពោះអ្នក
ដូចកូនបានពោលពាក្យសច្ចៈ
ជូនដោយគារវៈពេលនេះហោង ។